

# ការចិញ្ចឹមកូនបែបវិជ្ជមាន

## ១. សេចក្ដីផ្ដើម

ការផ្ដល់នូវការយកចិត្តទុកដាក់ ការថែទាំ ការការពារ ការផ្ដល់ក្ដីស្រឡាញ់ ការផ្ដល់ចំណីអាហារ និងការអប់រំប្រៀនប្រដៅកូន ឬកុមារ គេហៅថាកាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការចិញ្ចឹមបីបាច់កូន ឬកុមារ។ការចិញ្ចឹមកូនបែបវិជ្ជមានគឺជាវិធីសាស្ត្រមួយដ៏សំខាន់ដើម្បីទប់ស្កាត់ និងកាត់បន្ថយគម្លាតយេនឌ័រនិងអំពើហិង្សាលើកុមារ។



កុមារត្រូវការភាពកក់ក្ដៅ និងក្ដីស្រឡាញ់ពីឪពុកម្ដាយ

## ២. គោលការណ៍មិនប្រើហិង្សា

ឪពុកម្ដាយគួរមានគោលការណ៍ ឬជាក្រមសីលធម៌នៃការអប់រំកុមារដោយមិនមានអំពើហិង្សា។ ឪពុកម្ដាយត្រូវអប់រំកុមារឱ្យដឹងថា គេនឹងទទួលផលវិបាក បើសិនជាគេធ្វើអ្វីមួយដែលមិនត្រឹមត្រូវ ឬដែលយើងមិនចង់បាន។





## ផលប៉ះពាល់នៃការប្រើអំពើហិង្សាលើកុមារ




ការរំលោភបំពានគ្រប់ប្រភេទ សុទ្ធតែប៉ះពាល់ដល់កុមារ ដែលបណ្ដាលឱ្យ៖

- ភ័យខ្លាច
- បាត់បង់ទំនុកចិត្ត
- រងរបួស ឬមានជំងឺ
- គិតថាខ្លួនគ្មានតម្លៃ
- ខូចចិត្ត
- អស់សង្ឃឹម
- ខួរក្បាលនិងរាងកាយអភិវឌ្ឍយឺត។ល។

## ៣. ភាតព្វកិច្ចឪពុកម្ដាយចំពោះកូន

ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមានកាតព្វកិច្ច ចាប់តាំងពីកូនឬកុមារបង្កកំណើតរហូតដល់ពេញវ័យ ។



១.ការពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ
២.ការបំបៅដោះកូន
៣.ការចុះសំបុត្រកំណើត
៤.ការថែទាំសុខភាពកូន
៥.ការកំណត់គោលដៅរយៈពេលវែង
៦.ការការពារ និងសុវត្ថិភាពនៃការលេង
៧.ការធ្វើជាគំរូល្អ
៨.ការផ្ដល់ឱកាស
៩.ការបង្រៀន និងអប់រំ
១០.ការផ្ដល់ភាពកក់ក្ដៅ និងក្ដីស្រឡាញ់
១១.ការធ្វើការងារផ្ទះ
១២.ការរស់នៅចុះសម្រុងគ្នា
១៣.អាកប្បកិរិយា និងឥរិយាបថល្អ

## ៤. គោលការណ៍នៃការប្រៀនប្រដៅកូនបែបវិជ្ជមាន

### គោលការណ៍ទី១៖ ភាពអហិង្សា

មិនប្រើទម្រង់ណាមួយនៃអំពើហិង្សាលើកុមារ



### គោលការណ៍ទី២៖ ផ្ដោតលើការដោះស្រាយបញ្ហា



ដោះស្រាយប្រកបដោយសន្តិវិធីដែលមានការយល់ព្រមចូលរួមនិងការចរចារគ្នា

### គោលការណ៍ទី៣៖ ការគោរព

គឺជាការឱ្យតម្លៃស្មើៗគ្នាក្នុងភាពជាមនុស្សដោយគ្មានការរើសអើងនិងវិនិច្ឆ័យ



### គោលការណ៍ទី៤ ៖ ផ្ដែកលើការលូតលាស់និងអភិវឌ្ឍកុមារ



ការលូតលាស់និងការអភិវឌ្ឍកុមារមានភាពខុសគ្នាទៅតាមផ្នែករាងកាយ សតិបញ្ញា ស្មារតី ចរិតលក្ខណៈនិងអារម្មណ៍ទៅតាមតម្រូវការរបស់ពួកគេ

### គោលការណ៍ទី៥៖ ផ្អែកលើសិទ្ធិកុមារ



ត្រូវធានាថាកុមារមានសុវត្ថិភាព សុខភាពល្អ សប្បាយរីករាយ ទទួលការអប់រំនិងនិយាយអ្វីដែលមានសារៈសំខាន់

ការប្រៀនប្រដៅកូនបែបវិជ្ជមាន មានធាតុផ្សំសំខាន់៤ គឺ ការកំណត់គោលដៅយូរអង្វែងពេលកូនធំឡើង ភាពកក់ក្ដៅនិងដែនកំណត់ ការយល់ពីការគិត និងអារម្មណ៍របស់កូន និងការបង្រៀនឱ្យកូនចេះដោះស្រាយបញ្ហាដោយសន្តិវិធី។

សម្គាល់៖ ឯកសារនេះត្រូវបានផលិតឡើងក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្វ្លេមីស៍។ខ្លឹមសារនៃឯកសារនេះស្ថិតក្រោមការទទួលខុសត្រូវរបស់VVOB – ការអប់រំដើម្បីអភិវឌ្ឍន៍ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ទាំងនេះទេ ។

រៀបចំដោយ

vvob education for development

ឧបត្ថម្ភដោយ

Belgium partner in development

Flanders State of the Art